**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ......៨៣២......អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ, ថ្ងៃទី១៣ខែមករា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានពន្ធដារសូមជម្រាបជូនដំណឹងដល់សាធារណជន ម្ចាស់យានយន្តទាំងអស់មេត្តាជ្រាបថា ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៦ ត្រូវបានបិទបញ្ចប់ជាស្ថាពរហើយ កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ កន្លងទៅ ស្របតាមប្រកាសលេខ ៧១០ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ផ្អែកតាមប្រកាសលេខ ៧១០ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ និងតាមរយៈចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៧ លើលិខិតលេខ ១១១៣៥ សហវ.អពដ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានពន្ធដារ សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច នឹងចុះត្រួតពិនិត្យតាមគោលដៅនីមួយៗ ស្តីពីការអនុវត្តប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ តទៅ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស សំដៅធានាបាននូវប្រសិទ្ធភាព សមភាព និងតម្លាភាព នៃការប្រមូលចំណូលពន្ធ។ ក្នុងករណីពិនិត្យឃើញថា មិនទាន់បានបង់ពន្ធត្រឹមត្រូវទេ អគ្គនាយកដ្ឋានពន្ធដារនឹងធ្វើការផាកពិន័យនៅហ្នឹងកន្លែងត្រួតពិនិត្យ ចំពោះរថយន្តទាំងឡាយដែលខកខានមិនបានប្រកាសបង់ពន្ធ មុន ឬត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។

អគ្គនាយកដ្ឋានពន្ធដារក៏សូមជម្រាបជូនសាធារណជន ម្ចាស់យានយន្ត មេត្តាជ្រាបផងដែរថា ការចុះត្រួតពិនិត្យការអនុវត្តប្រមូលពន្ធប្រភេទនេះ ត្រូវបានធ្វើឡើងដោយការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាទំនើបសម្រាប់ ស្កែនលតាបត្រពន្ធបិទភ្ជាប់នឹងយានយន្តដែលកំពុងចរាចរលើដងផ្លូវ។ ករណីរកឃើញយានយន្តដែលមិនទាន់បានប្រកាសបង់ពន្ធ ក្រុមការងារចម្រុះនៃអគ្គនាយកដ្ឋានពន្ធដារនឹងបញ្ចៀសឱ្យទៅចតផុតពីដងផ្លូវសាធារណៈ ដើម្បីឱ្យម្ចាស់យានយន្តនោះងាយស្រួលបំពេញបែបបទបង់ប្រាក់ពន្ធនិងប្រាក់ពិន័យស្របតាមច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ម្ចាស់រថយន្តទាំងអស់ មេត្តាជ្រាប និងចូលរួមអនុវត្តច្បាប់ប្រកបដោយស្មារតីសហការ និងការទទួលខុសត្រូវខ្ពស់។

**អគ្គនាយកដ្ឋានពន្ធដារ**

Collection by VCAT Professional Consultant